ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០១៣......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយស សូមប្រកាសជូនដំណឹង ដល់លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាស អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ជាពិសេសសហគ្រាសដែលកំពុងធ្វើប្រតិបត្តិការនាំចេញ-នាំចូល មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមវាយតម្លៃខ្ពស់ចំពោះសហគ្រាសដែលយកអស់ស្មារតីទទួលខុសត្រូវ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួន តាមការតម្រូវនៃច្បាប់ ។ ប៉ុន្តែក្នុងនោះក៏ពិនិត្យឃើញថាមានសហគ្រាសមួយចំនួន ធ្វើសកម្មភាពអាជីវកម្មមិនបានមកចុះបញ្ជី មិនប្រកាសបង់ពន្ធនៅឡើយ ឬប្រកាសបង់ពន្ធមិនត្រឹមត្រូវទៅតាមបរិមាណ និងតម្លៃទំនិញដែលខ្លួនបានលក់ ក្នុងគោលបំណងគេចវេះពន្ធ បន្ថយឬបំបាត់ប្រាក់ពន្ធ ដែលជាការអនុវត្តមិនបានត្រឹមត្រូវទៅតាមការតម្រូវនៃច្បាប់ និងសហគ្រាសខ្លះទៀតជំពាក់បំណុលពន្ធ ហើយទោះបីរដ្ឋបាលសារពើពន្ធកោះអញ្ជើញឲ្យមកដោះស្រាយ ក៏នៅព្រងើយកន្តើយ រឹងរូសមិនព្រមមកទូទាត់បំណុលពន្ធដែលខ្លួនបានជំពាក់ឡើយ ។

ក្នុងឆ្នាំ២០១០នេះ ការត្រួតពិនិត្យសារពើពន្ធ ត្រូវបានពង្រឹងថែមទៀត ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការបង្កើនការគោរពប្រតិបត្តិច្បាប់សារពើពន្ធ នឹងដើម្បីធ្វើឲ្យមានយុត្តិធម៌ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ។ រាល់ការលាក់លៀម ការកសាងកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗដែលរកឃើញ នឹងត្រូវរងនូវការកំណត់ពន្ធឡើងវិញ ដែលរួមមានប្រាក់ពន្ធដែលបង់ខ្វះ ពន្ធបន្ថែម និងការប្រាក់ ដូចមានចែងក្នុងមាត្រា១១៦, មាត្រា១១៧, មាត្រា១៣១, មាត្រា១៣២ និងមាត្រា១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ។ ក្រៅពីនេះ ការគេចវេះពន្ធ ការធ្វើឲ្យរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ឬការជ្រោមជ្រែងអូសទាញឲ្យប្រព្រឹត្តបទល្មើស គឺជាការប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ ឬជាប់ពន្ធនាគារ ឬទោសទាំងពីរនេះ ដូចមានចែងក្នុង មាត្រា១២៧, មាត្រា១២៨, មាត្រា១២៩, មាត្រា១៣៥, មាត្រា១៣៦ និងមាត្រា១៣៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

ម្យ៉ាងទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមរំលឹកចំពោះសហគ្រាសដែលនៅជំពាក់បំណុលពន្ធ សូមរួសរាន់ជំរះបំណុលឲ្យបានរួចរាល់ តាមកាលកំណត់ ។ វិធានការតឹងទារ នឹងត្រូវអនុវត្តចំពោះសហគ្រាសយឺតយ៉ាវក្នុងការទូទាត់បំណុល ដែលរួមមានការឃុំគ្រង ការរឹបអូសទ្រព្យសម្បត្តិ ការឃាត់ទុកគណនីធនាគារ ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រា១០៩, មាត្រា១១១, មាត្រា១១៣, មាត្រា១១៤ និងមាត្រា១១៥ នៃច្បាប់ស្តីពីសារពើពន្ធ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹម និងជឿជាក់ថា សហគ្រាសទាំងឡាយដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ តាមច្បាប់ជាធរមាន ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com